ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

លេខ ៩០ "ខ១" ក្រ.៨

ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ ១៦៦៨

ចុះថ្ងៃ១៦ ខែមេសា ឆ្នាំ២០២១

**សំណុំរឿងស៊ើបសួរ**

លេខ ១២៤៩

ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១

**ជំនុំជម្រះ**

លេខ ៤២៩៤

ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈនាថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២

វេលាម៉ោង ០២ និង ៣០ នាទី រសៀល សាលសវនាការទី៤ ជាន់ទី១

ដោយមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ

លោក [redacted] ចៅក្រមប្រឹក្សានៃសាលាដំបូងរាជធានីភ្នំពេញ

លោក [redacted] ចៅក្រមប្រឹក្សានៃសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ

**ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៦៦៨ ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖**

ឈ្មោះ [redacted] **ស្រស់** ហៅ **ស្រស់** ភេទប្រុស អាយុ ២២ឆ្នាំ ជនជាតិខ្មែរ សញ្ញាតិខ្មែរ មុខរបរកម្មករ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូ[redacted] រាជធានីភ្នំពេញ មុនពេលឃាត់ខ្លួនស្នាក់នៅភូមិ[redacted]រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ចាន់ "រស់" ម្តាយឈ្មោះ [redacted] ពៅ "រស់" នៅលើវ ជានីតិជន ទោសពីមុនគ្មាន ។ (ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៩១០ "ច១" ដ.ឃ.ដ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១)

ជាប់ចោទពីបទ **លួចដោយមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចម្តុំគល់ស្ពានម៉ុងឬទ្ធី ផ្លូវលេខ១៩២៨ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ មេធាវី [redacted] អត្តលេខ [redacted] មានការិយាល័យនៅអាគារការិយាល័យវឌ្ឍនៈ ជាន់ទី១៧ លេខ៦៦ មហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ចាន់នឿន** ភេទស្រី អាយុ ១៩ឆ្នាំ សញ្ញាតិខ្មែរ ជនជាតិខ្មែរ មុខរបរអ្នកលក់បន្លែ ទីលំនៅបច្ចុប្បន្ននៅបន្ទប់ជួល ផ្លូវបេតុង សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ១៥ និង០០នាទី នៅចំណុចម្តុំគល់ស្ពានម៉ុងឬទ្ធី ផ្លូវលេខ



Scanned with CamScanner

១៩២៨ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឈ្មោះ [redacted] **ស្រស់** ហៅ **ស្រស់** ភេទប្រុស អាយុ ២២ឆ្នាំ បានជិះម៉ូតូមួយគ្រឿងម៉ាក សេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៥ លេខតួ និងម៉ាស៊ីន ៩៤២៧៦០២ ពាក់ស្លាកលេខ ស្វាយរៀង 1P-9743 (ជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] **ស្រស់**) ចេញរកមើលទ្រព្យសម្បត្តិ និងសម្ភារៈរបស់ប្រជាពលរដ្ឋតាមដងផ្លូវក្នុងរាជធានីភ្នំពេញ ។ នៅពេលធ្វើដំណើរតាមបណ្តោយផ្លូវ១៩២៨ ពីទិសខាងកើតទៅទិសខាងលិចដល់ចំណុចគល់ស្ពានម៉ុងឬទ្ធី ក៏ឃើញដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ចាន់នឿន** ភេទស្រី អាយុ ១៩ឆ្នាំ ជិះនៅកណ្តាលលើម៉ូតូមួយគ្រឿងម៉ាកសេ១២៥ ពណ៌ខ្មៅ ដោយទុកទូរស័ព្ទដៃម៉ាកអូប៉ូ ពណ៌ក្រហម នៅហោប៉ៅខោខាងឆ្វេង ។ ភ្លាមៗនោះឈ្មោះ [redacted] **ស្រស់** ក៏បើកម៉ូតូទៅអែបទន្ទឹមខាងឆ្វេងដៃម៉ូតូដើមបណ្តឹងរដ្ឋប្បវេណី រួចក៏ធ្វើសកម្មភាពយកដៃស្តាំលូកឆក់យកទូរស័ព្ទរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានសម្រេច ។ បន្ទាប់មកឈ្មោះ [redacted] **ស្រស់** ក៏បន្ថែមល្បឿនម៉ូតូគេចខ្លួន ចំណែកដើមបណ្តឹងរដ្ឋប្បវេណីក៏ស្រែកថា "ចោរៗ" ស្របពេលនោះ សមត្ថកិច្ចប៉ុស្តិ៍នគរបាលភ្នំពេញថ្មី កំពុងល្បាតក៏អន្តរាគមន៍ដេញតាមពីក្រោយឈ្មោះ [redacted] **ស្រស់** រហូតឃាត់ខ្លួនឈ្មោះ [redacted] **ស្រស់** បាន និងដកហូតទូរស័ព្ទដៃមកវិញ ។ បន្ទាប់មកសមត្ថកិច្ចអធិការដ្ឋាននគរបាលខណ្ឌសែនសុខ ក៏សាកសួរ និងកសាងសំណុំរឿងបញ្ជូនមកកាន់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ៣៦៥៤ អ.យ.ធ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១ ។

**-បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៩៣០ "គ" ដ.ង ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ ២០២១ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **ស្រស់** បានឆ្លើយសារភាពថា៖ នៅរសៀលថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ ខ្លួនជិះម៉ូតូម៉ាកសេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៥ លេខតួ និងម៉ាស៊ីន ៩៤២៧៦០២ ពាក់ស្លាកលេខ ស្វាយរៀង 1P-9743 តែម្នាក់ឯងចេញពីផ្ទះទៅធ្វើសកម្មភាពឆក់យកទ្រព្យសម្បត្តិ និងសម្ភារៈរបស់ប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ ។ នៅពេលខ្លួនធ្វើដំណើរតាមបណ្តោយផ្លូវបេតុងលេខ១៩២៨ ពីទិសខាងកើតទៅទិសខាងលិច ដល់ចំណុចគល់ស្ពានម៉ុងឬទ្ធី ក៏ឃើញមនុស្សស្រីចំនួន ៣នាក់ ជិះម៉ូតូ ១គ្រឿង ដោយមនុស្សស្រីម្នាក់ជិះក្រោយមានទូរស័ព្ទដៃទុកនៅហោប៉ៅខោខាងក្រោយ ។ ភ្លាមៗនោះខ្លួនក៏បើកម៉ូតូទៅអែបទន្ទឹមខាងឆ្វេងដៃម៉ូតូមនុស្សស្រី រួចធ្វើសកម្មភាពយកដៃស្តាំលូកឆក់យកទូរស័ព្ទដៃបានសម្រេចក៏បន្ថែមល្បឿនម៉ូតូគេចខ្លួន ។ ជនរងគ្រោះបានស្រែកខ្លាំងៗថា៖ "ចោរៗ" ផ្អើលដល់អ្នកធ្វើដំណើរ ហើយសមត្ថកិច្ចល្បាតក៏ដេញតាមពីក្រោយខ្លួន រហូតឃាត់ខ្លួនបាន និងដកហូតទូរស័ព្ទដៃយកទៅវិញ រួមទាំងម៉ូតូដែលជាមធ្យោបាយ ។

-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ចាន់នឿន** នៅដំណាក់កាលសមត្ថកិច្ចបានឆ្លើយថា៖ នៅរសៀលថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ មិត្តភក្តិរបស់ខ្លួន បានបើកម៉ូតូម៉ាកសេ១២៥ ពណ៌ខ្មៅ ឌុបខ្លួន (ជិះកណ្តាល) និងមិត្តភក្តិម្នាក់ទៀតជិះក្រោយ ដោយខ្លួនបានទុកទូរស័ព្ទដៃម៉ាកអូប៉ូ ពណ៌ក្រហម នៅក្នុងហោប៉ៅខោខាងក្រោយ មកដល់ចំណុចគល់ស្ពានម៉ុងឬទ្ធី ស្រាប់តែមានមនុស្សប្រុសម្នាក់ជិះម៉ូតូតែម្នាក់ឯងមកអែបទន្ទឹមខាងឆ្វេងដៃម៉ូតូខ្លួន រួចមនុស្សប្រុសនោះក៏បានធ្វើសកម្មភាពលូកចាប់ឆក់ទូរស័ព្ទដៃពីក្នុងហោប៉ៅខោខ្លួនបានសម្រេច រួចបន្ថែមល្បឿនម៉ូតូទៅមុខ ។ ភ្លាមៗនោះខ្លួនក៏ស្រែកខ្លាំងៗថា៖ "ចោរៗ" ផ្អើលដល់អ្នកធ្វើដំណើរតាមដងផ្លូវ ហើយសមត្ថកិច្ចល្បាតក៏ជួយអន្តរាគមន៍ដេញឃាត់មនុស្សប្រុសនោះបាន ។ បន្ទាប់មកខ្លួនបានមកដាក់ពាក្យបណ្តឹងប៉ុស្តិ៍នគរបាលរដ្ឋបាលភ្នំពេញថ្មីតែម្តង ។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីការសួរដេញដោលនាពេលសវនាការ ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងពិនិត្យភស្តុតាង ឃើញថា ចម្លើយរបស់ជនជាប់ចោទមានភាពស៊ីសង្វាក់ភស្តុតាងដែលមានក្នុងសំណុំរឿង បង្ហាញថាជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតប្រាកដមែន ។ តំណាងអយ្យការសុំតម្កល់សេចក្តីចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរទុកជាបានការទាំងស្រុង និងស្នើសុំតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ស្រស់ បានធ្វើសេចក្តីសន្និដ្ឋានថា៖ តាមរបាយការណ៍ស៊ើបអង្កេត តាមការសាកសួរដេញដោល និងតាមការសារភាពរបស់ជនជាប់ចោទ ឃើញថា មានសកម្មភាពលួចទ្រព្យសម្បត្តិពីជនរងគ្រោះពិតប្រាកដមែន តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ ។ ចាប់ពីដើមមកជនជាប់ចោទបានសហការណ៍ផ្តល់ចម្លើយដល់សមត្ថកិច្ចរហូត ហើយមិនធ្លាប់មានប្រវត្តិប្រព្រឹត្តបទល្មើសពីមុនមកទេ ។ នៅថ្ងៃកើតហេតុជនជាប់ចោទមិនបានគិតទុកជាមុនក្នុងការធ្វើសកម្មភាពនោះទេ វាកើតឡើងដោយសារជនជាប់ចោទមានគំនិតខ្លីមួយពេល ព្រោះត្រូវការប្រាក់យកទៅព្យាបាលបងប្រុសគ្រោះថ្នាក់ចរាចរណ៍ ។ នៅពេលនេះជនជាប់ចោទបានដឹងកំហុស ហើយសន្យាធ្វើជាពលរដ្ឋល្អរបស់សង្គមឡើងវិញ ។ សកម្មភាពជនជាប់ចោទមិនមែនជាអំពើហិង្សាបង្ករបួសស្នាម ឬកាប់គាស់ទម្លុះទម្លាយដែលចាត់ទុកជាស្ថានភាពស្ថានទម្ងន់ទោសតាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ដូច្នេះ ខ្លួនសូមស្នើសុំតុលាការកែប្រែការចោទប្រកាន់ដោយចោទត្រឹមបទ លួច តាមបញ្ញត្តិមាត្រា ៣៥៣ និង មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ និងសម្រេចបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង ។

## សម្តីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទ ឈ្មោះ [redacted] ស្រស់ បានសំណូមពរសុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផង ពីព្រោះខ្លួនប្រព្រឹត្តកំហុសដោយសារខ្លួនត្រូវការប្រាក់យកទៅព្យាបាលបងប្រុសគ្រោះថ្នាក់ចរាចរណ៍ ហើយមិនបានគិតគូរវែងឆ្ងាយ ពេលនេះខ្លួនដឹងកំហុសហើយ ។

-ក្រោយពីបានសួរដេញដោលក្នុងអង្គសវនាការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងនិងពិចារណាលើសំណុំរឿងត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

-តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៩៣០ "គ" ដ.ដ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ ចៅក្រមស៊ើបសួរបានបញ្ជូនជនជាប់ចោទ ឈ្មោះ [redacted] ស្រស់ ភេទប្រុស អាយុ ២២ឆ្នាំ ជនជាតិខ្មែរ ទៅជំនុំជម្រះ ពីបទ **លួចដោយមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចម្តុំគល់ស្ពានម៉ុងឫទ្ធី ផ្លូវលេខ ១៩២៨ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

-ជនជាប់ចោទ ឈ្មោះ [redacted] ស្រស់ បានទទួលស្គាល់ថា ខ្លួនពិតជាបានធ្វើសកម្មភាពឆក់ទ្រព្យសម្បត្តិពីក្នុងហោប៉ៅរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់ធឿន ប្រាកដមែន ។



Scanned with CamScanner

-តាមរបាយការណ៍របស់សមត្ថកិច្ចនគរបាលយុត្តិធម៌ ចម្លើយសារភាពរបស់ជនជាប់ចោទ អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងភស្តុតាងដែលមានក្នុងសំណុំរឿង មានភាពស៊ីសង្វាក់ក្នុងការបញ្ជាក់ថាកាលពីថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ នៅចំណុចមុំគល់ស្ពានម៉ុងឬទ្ធី ផ្លូវលេខ១៩២៨ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឈ្មោះ [redacted] **ស្រស់** ពិតជាបានធ្វើសកម្មភាពឆក់ (ទូរស័ព្ទដៃ) របស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងបំណងចាត់ចែងជាទ្រព្យរបស់ខ្លួន មែន ។

-យោងតាមបញ្ញត្តិមាត្រា **៣៥៣** នៃក្រមព្រហ្មទណ្ឌ អំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធរបស់ខ្លួន ជា **អំពើលួច** ។

-យោងតាមបញ្ញត្តិមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ អំពើលួចមានស្ថានទម្ងន់ទោស កាលបើអំពើលួចនេះប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬក្រោយពេលប្រើអំពើហិង្សា ឬអំពើលួចនេះ ប្រព្រឹត្តដោយការកាប់គាស់ទម្លុះទម្លាយ ។

-អំពើរបស់ជនជាប់ចោទដែលបានដកហូតដោយទុច្ចរិតតាមវិធីហិង្សា (ដកយកចេញទៅដោយហិង្សា) នូវទ្រព្យសម្បត្តិរបស់អ្នកដទៃ (ទូរស័ព្ទដៃរបស់ឈ្មោះ [redacted] **ចាន់ធឿន**) ក្នុងគោលបំណងចាត់ចែងជាកម្មសិទ្ធិរបស់ខ្លួន គឺជាបទល្មើស **លួចដោយមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ។

-ជនជាប់ចោទ ជានីតិជន នាពេលប្រព្រឹត្តបទល្មើស ស្ថិតក្នុងស្ថានភាពដែលអាចយល់ដឹងអំពីលទ្ធផលតាមផ្លូវច្បាប់ចំពោះអំពើរបស់ខ្លួនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការមានភាពសមហេតុផលគប្បីតុលាការលើកយកមកពិចារណា។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ មានសំអាងខ្លះអាចឱ្យតុលាការជឿជាក់បាន ប៉ុន្តែសំអាងខ្លះមិនគ្រប់គ្រាន់មិនអាចឱ្យតុលាការជឿជាក់បានឡើយ ។

-មានពិរុទ្ធគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ស្រស់ ភេទប្រុស អាយុ ២២ឆ្នាំ ពីបទ **លួចដោយមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចមុំគល់ស្ពានម៉ុងឬទ្ធី ផ្លូវលេខ១៩២៨ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

-ភាគីដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ពាក្យបណ្តឹងចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ នៅដំណាក់កាលសមត្ថកិច្ច ដោយមិនបានធ្វើការទាមទារសំណងរដ្ឋប្បវេណី ដូចនេះតុលាការគប្បីមិនពិចារណាលើសំណងរដ្ឋប្បវេណីនោះទេ ។

-តាមកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៧៥៩ រ.វ.ត ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២១ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ឃើញថា វត្ថុចាប់យក ម៉ូតូ ម៉ាកសេ១២៥ ពណ៌ខ្មៅ ផ្លាកលេខស្វាយរៀង 1P-9743 ចំនួន ០១គ្រឿង (មិនប្រក្រតី) ជាទ្រព្យសម្បត្តិ ដែលត្រូវបានកាន់កាប់ដោយខុសច្បាប់ ឬជាមធ្យោបាយប្រព្រឹត្តបទល្មើស គប្បីសម្រេចរឹបអូស ។

<u>**ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី**</u>

**១-ផ្តន្ទាទោសឈ្មោះ** [redacted] **ស្រស់** ហៅ **ស្រស់** ភេទប្រុស អាយុ ២២ឆ្នាំ ជនជាតិខ្មែរ ដែលមានអត្តសញ្ញាណខាងលើ ដាក់ពន្ធនាគារកំណត់ ០៤ (បួន) **ឆ្នាំ** ពីបទ **លួចដោយមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចមុំគល់ស្ពានម៉ុងឬទ្ធី ផ្លូវលេខ១៩២៨ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

**២-រឹបអូសវត្ថុចាប់យក៖** ម៉ូតូ ម៉ាកសេ ១២៥ ពណ៌ខ្មៅ ផ្លាកលេខស្វាយរៀង 1P-9743 ចំនួន ០១គ្រឿង (មិនប្រក្រតី) ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ស្រស់ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

**បានឃើញ**

ថ្ងៃសុក្រ ០២រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃសុក្រ ០២រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner